# ក្រសួងឧស្សាហកម្ម និងក្រុមហ៊ុន Worldbridge International Cambodia Ltd ចុះអនុស្សារណៈស្តីពីការបង្កើតសួនអេកូសហគ្រាសធុនតូចនិងមធ្យម

( SME Eco Park )

យោងតាមគោលនយោបាយអភិវឌ្ឍន៏វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥ ដែលក្នុងនោះ បានកំណត់ទិសដៅពង្រឹងយន្តការគ្រប់គ្រង និងអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម និងអនុលោម តាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជម្រុញគម្រោង វិនិយោគតាមទម្រង់ភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) នារសៀលថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០១៦ នៅសាលប្រជុំរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានរៀបចំពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា ស្តីពីការបង្កើតសួនអេកូសហគ្រាសធុនតូចនិងមធ្យម (SME Eco Park) រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រុមហ៊ុន Worldbridge International Cambodia Ltd ។

ហត្ថលេខីនៃពិធីនោះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចុះហត្ថលេខាដោយ**ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង ក្រុមហ៊ុន Worldbridge International Cambodia Ltd ចុះហត្ថលេខាដោយ **លោក ឧកញ៉ា សៀ ឫទ្ធី** ប្រធានក្រុមប្រឹក្សា ភិបាលក្រុមហ៊ុន ក្រុមហ៊ុន Worldbridge International Cambodia Ltd ។

មានប្រសាសន៍នាឱកាសនោះ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានចាត់ទុកជាសមិទ្ធិផល ផ្លែផ្កាជាលើកដំបូង និងជាគំរូ ក្នុងការរៀបចំប្រមូលផ្តុំ សហគ្រាសធុនតូច និងមធ្យម ដើម្បីធ្វើការផលិត តម្រង់ទិស ទៅរកទីផ្សារនាំចេញនូវផលិតផលដែលមានសក្តានុពល ប្រកបដោយគុណភាព និងឧត្តមភាពប្រកួតប្រជែង ជាមួយនឹងអត្ថប្រយោជន៍ជាច្រើនទៀត ដូចជាៈ ទទួលបានតម្លៃបន្ថែម ទីផ្សារការងារ និងការផ្ទេរបច្ចេក វិទ្យា ជាដើម ។ ម៉្យាងយើងមានជំនឿ ទៅលើការចាប់ដៃគូសហការ ជាមួយក្រុមហ៊ុន Worldbridge International Cambodia Ltd ដែលមានបទពិសោធន៍ ក្នុងរបរអាជីវកម្ម ទាំងក្នុង និងក្រៅប្រទេស ដោយក្រុមហ៊ុន មានទីផ្សារ មានដៃគូ មានធនធាន និងភស្តុភារគ្រប់គ្រាន់ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានបញ្ជាក់ថាៈ ប្រទេសយើងជាប្រទេសកសិកម្ម ជាប្រភពនៃវត្ថុធាតុដើម ដូច្នេះការអភិវឌ្ឍន៍វិស័យសហគ្រាសខ្នាតតូច និងមធ្យម ជាលក្ខណៈ ចង្កោម ដើម្បីកែ ច្នៃផលិតនាំចេញ ត្រូវគិតថាជាគំនិតប្រាកដនិយមមួយ និងត្រូវធ្វើឲ្យបានសម្រេច ពីព្រោះយើងក៏មើលឃើញ នូវបទពិសោធន៍ពីប្រទេសជាច្រើនផងដែរ ។ជាពិសេស កម្ពុជា

មានទំនិញសក្តានុពល មួយចំនួនដែលអាចប្រកួតប្រជែងបាន ហើយយើងត្រូវចេះកែច្នៃធ្វើយ៉ាងណាឲ្យស្រប និងលក្ខខ័ណ្ឌតម្រូវនៃប្រទេសអ្នកនាំចូល។ ផលិតផលទាំងនោះ មានតាំងពីបន្លែផ្លែឈើ ត្រី សាច់ គ្រឿងសមុទ្រ និងកៅស៊ូ ជាដើម ។

**លោកឧកញ៉ា សៀ ឬទ្ធី** បានបង្ហាញនូវមោទនភាពដែលគ្រោងការនេះ ទទួលបានការគាំទ្រសហការពេញទំហឹងពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ព្រោះគំនិតផ្តួចផ្តើមរបស់លោកឧកញ៉ាយូរមកហើយទើបដល់គោលដៅ នៅពេលនេះ ។ លោកឧកញ៉ា ប្តេជ្ញាសម្រេចឲ្យបានជោគជ័យនូវគ្រោងការនេះ ព្រោះក្រុមហ៊ុន មានធនធានមនុស្ស ធនធានថវិកា បទពិសោធន៍ និងដៃគូសហការជាច្រើននៅក្រៅប្រទេស ។ យោងតាមខ្លឹមសារនៃអនុស្សារណៈ ការបង្កើតសួនអេកូសហគ្រាសធុនតូចនិងមធ្យមនេះ គឺបានជ្រើសរើសទីតាំងនៅភូមិស្វាយរលំ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ។ ចំពោះការទទួលខុសត្រូវ ក្រសួងសម្របសម្រួលជាមួយ ក្រសួងស្ថាប័នពាក់ព័ន្ធនានា ដើម្បីស្វែងរកការទ្រទ្រង់ដល់ការលើកទឹកចិត្ត ក្នុងការវិនិយោគ សម្របសម្រួលរាល់បែបបទ និងស្វែងរកដៃគូអភិវឌ្ឍន៍អាជីវកម្មនានា ដើម្បីជួយសម្រួល ដល់កិច្ចដំណើរការសួនអេកូសហគ្រាសធុនតូច និងមធ្យមឲ្យបានជោគជ័យជាដើម ។

ចំណែកភាគីក្រុមហ៊ុន មានការទទួលខុសត្រូវដូចជាៈ សហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការសិក្សាលើបញ្ហាប្រឈមរបស់សមាជិក ទីតាំងតំបន់ ការសិក្សាសមិទ្ធិលទ្ធភាព និងផែនការមេរួមទាំងការវាយតម្លៃគម្រោង និងទទួលសេចក្តីណែនាំពីក្រសួង លើការផ្តល់ជាតុចូល និងការកសាងគម្រោង សំដៅជានាសុវត្ថិភាពនិងនិរន្តរភាពក្នុងសួន អេកូសហគ្រាសធុនតូច និងមធ្យម។




អនុស្សារណៈយោគយល់គ្នា
ស្តីពី
ការបង្កើតសួនអេកូសហគ្រាសធុនតូច និងមធ្យម
(SME Eco Park)
រវាង




អនុស្សរណៈនៃការយោគយល់គ្នា
ស្តីពី
ការបង្កើតសួនអេកូសហគ្រាសធុនតូច និងមធ្យម
(SME Eco Park)
រវាង









